Dai-ichi Life
នៅក្បែរអ្នកជានិច្ច

# គម្រោងឌីជីថល BrightLife
# ប្រាយឡាយហ្វ៍
តាមរយៈការធានារ៉ាប់រង ធ្វើឱ្យជីវិតកាន់តែស្រស់បំព្រង



## មូលហេតុ៣យ៉ាង
### ដែលលោកអ្នកគួរទិញ ប្រាយឡាយហ្វ៍

**មានភាពងាយស្រួលក្នុងការទទួលបានការការពារអាយុជីវិត៖**
ទិញភ្លាម ទទួលបានការការពារអាយុជីវិតភ្លែត

**ផ្តល់ការការពាររយៈ ខ្លី**
ផ្តល់ការការពារក្នុងរយៈពេល 1 ឆ្នាំពេញ

**មានតម្លៃសមរម្យ៖**
តម្លៃបុព្វលាភរ៉ាប់រងសម្យរម្យ
សម្រាប់ការការពារអាយុជីវិតរយៈពេលខ្លី

**កម្មវត្ថុនៃការធានារ៉ាប់រង** របស់គម្រោង **ប្រាយឡាយហ្វ៍ BrightLife** គឺធានាទៅលើអាយុជីវិតរបស់អ្នកត្រូវបានធានា ពីមរណភាព ឬពិការភាពទាំងស្រុង និងអចិន្ត្រៃយ៍។

**វិសាលភាពនៃការធានារ៉ាប់រង** របស់គម្រោងនេះ គឺធានាអាយុជីវិតអ្នកត្រូវបានធានារ៉ាប់រងទៅលើហានិភ័យមរណភាព ឬពិការភាពទាំងស្រុង និងអចិន្ត្រៃយ៍ ដែលបណ្តាលមកពីហេតុការណ៍ទាំងអស់(លើកលែងតែហេតុការណ៍ទាំងឡាយណាដែលមានចែងនៅក្នុងករណីមិនធានា)។

លោកអ្នកអាចបង់បុព្វលាភធានារ៉ាប់រងតែមួយដងគត់ទៅឲ្យ **ក្រុមហ៊ុន ដាយ អ៊ិឈិ ឡាយហ្វ៍**

**លោកអ្នកអាចជ្រើសរើសបង់បុព្វលាភធានារ៉ាប់រងតាមរយៈ៖**
ការផ្ទេរប្រាក់ចូលគណនីធនាគាររបស់ក្រុមហ៊ុន
ដាយ អ៊ិឈិ ឡាយហ្វ៍ អ៊ីនស្ហូរ៉ិនស៍ (ខេមបូឌា) ម.ក
ឬ បញ្ជាបង់ប្រាក់អចិន្ត្រៃយ៍ ឬ ផ្សេងៗ។

### ករណីដែលមិនធានា

ក្នុងករណីទទួលមរណភាព ឬពិការភាពទាំងស្រុង និងអចិន្ត្រៃយ៍ ក្រុមហ៊ុន ដាយ អ៊ិឈិ ឡាយហ្វ៍ នឹងមិនទូទាត់អត្ថប្រយោជន៍ធានារ៉ាប់រងនៃបណ្ណសន្យារ៉ាប់រងនេះឡើយ ប្រសិនបើមរណភាព ឬពិការភាពទាំងស្រុង និងអចិន្ត្រៃយ៍របស់អ្នកត្រូវបានធានារ៉ាប់រងកើតឡើងដោយសារមូលហេតុណាមួយ ទោះបីដោយផ្ទាល់ ឬដោយប្រយោលក្តី ក្នុងចំណោមហេតុការណ៍ដូចខាងក្រោម៖

ក. អត្តឃាតដោយមិនគិតអំពីស្ថានភាពបញ្ហាស្មារតីរបស់អ្នកត្រូវបានធានារ៉ាប់រង ក្នុងរយៈពេល ២ (ពីរ)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចាប់ផ្តើមបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទការចាប់ផ្តើមមានសុពលភាពនៃការបន្តសុពលភាពឡើងវិញ ដោយយកកាលបរិច្ឆេទចុងក្រោយគេ ឬ
ខ. ការឆ្លងមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺដែលពាក់ព័ន្ធនឹងជំងឺអេដស៍ ឬ
គ. ការប្រើប្រាស់គ្រឿងញៀន ឬសារធាតុញៀនខុសច្បាប់ផ្សេងទៀត ឬ
ឃ.បទល្មើសព្រហ្មទណ្ឌ ដែលប្រព្រឹត្តដោយម្ចាស់បណ្ណសន្យារ៉ាប់រង ឬ អ្នកត្រូវបានធានារ៉ាប់រង ឬ អ្នកទទួលផល ឬ
ង. ពិការភាពកើតឡើងមុនពេលកាលបរិច្ឆេទចាប់ផ្តើមបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទបន្តសុពលភាពឡើងវិញ ឬ
ច. សង្គ្រាម (ប្រកាស ឬមិនបានប្រកាស) ភាពចលាចល ឬប្រតិបត្តិការសង្គ្រាម សង្គ្រាមស៊ីវិល ការបះបោរ ឬ ភាពវឹកវរក្នុងប្រទេស ឬ កុប្បកម្ម ឬ កូដកម្ម ឬ
ឆ. គ្រឿងផ្ទុះ ឬវិទ្យុសកម្មដោយសារតែអាវុធអាតូមិច នុយក្លេអ៊ែរ ឬអាវុធគីមី ឧបករណ៍ ឬគ្រឿងផ្ទុះកៃច្នៃ ឬ
ជ. មរណភាព ឬការរងរបួសដែលកើតឡើងខណៈពេល ឬដោយសារតែអ្នកត្រូវបានធានារ៉ាប់រងស្ថិតក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ឬថ្នាំញៀន ឬ
ឈ. ការជិះជាមួយ ឬបើកបរក្នុងការប្រណាំងកីឡាវិជ្ជាជីវៈណាមួយ ឬសកម្មភាពជ្រមុជទឹក ពាក់ព័ន្ធនឹងការប្រើប្រាស់ឧបករណ៍ដកដង្ហើម ឬ
ញ. សកម្មភាពហោះហើរ ឬអាកាសចរណ៍នានា លើកលែងតែការធ្វើដំណើរបង់ប្រាក់តាមយន្តហោះដែលមានអាជ្ញាបណ្ណត្រឹមត្រូវមានលក្ខណៈពាណិជ្ជកម្ម និងមានកាលវិភាគនៃការធ្វើដំណើរ។

**សូមមើល ខ និងលក្ខខណ្ឌបណ្ណសន្យារ៉ាប់រងសម្រាប់ព័ត៌មានលម្អិត*

**សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងទៅកាន់បុគ្គលិកលក់/ភ្នាក់ងារធានារ៉ាប់រង*

**ចំណាំ៖**
- ប្រសិនបើបុព្វលាភធានារ៉ាប់រងមិនត្រូវបានបង់នៅកាលបរិច្ឆេទកំណត់ត្រូវបង់បុព្វលាភរ៉ាប់រង នោះ ក្រុមហ៊ុន ដាយ អ៊ិឈិ ឡាយហ្វ៍ នឹងផ្តល់រយៈពេលអនុគ្រោះបន្ថែម ចំនួន ៣០ថ្ងៃ ជូនដល់អតិថិជនក្នុងការបង់នូវបុព្វលាភធានារ៉ាប់រងចុងក្រោយនោះ។
- ប្រសិនបើបណ្ណសន្យារ៉ាប់រងនេះត្រូវបានលុបចោលដោយសារតែការមិនបានបង់បុព្វលាភធានារ៉ាប់រង នោះម្ចាស់បណ្ណសន្យារ៉ាប់រងនឹងមិនត្រូវបានអនុញ្ញាតអោយធ្វើការស្នើសុំបន្តនូវសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញនោះឡើយ។

**ដាយ អ៊ិឈិ ឡាយហ្វ៍**
ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតរបស់ប្រទេសជប៉ុន
**ជាមួយប្រតិបត្តិការជាង១២២ឆ្នាំ**

## អំពីក្រុមហ៊ុន

**ដាយ អ៊ិឈិ ឡាយហ្វ៍ អ៊ីនស្ហួរិនស៍ (ខេមបូឌា) ម.ក** ដែលជាក្រុមហ៊ុន**បុត្រសម្ព័ន្ធរបស់ ដាយ អ៊ិឈិ ឡាយហ្វ៍ ហូលឌីង** គឺជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតឈានមុខគេមួយរបស់ប្រទេសជប៉ុនជាមួយ**ប្រតិបត្តិការជាង១២២ឆ្នាំ** នៅលើសាកលលោក។ **ក្រុមហ៊ុន ដាយ អ៊ិឈិ ឡាយហ្វ៍ ហូលឌីង** មានទីស្នាក់ការកណ្ដាលនៅ**ទីក្រុងតូក្យូ ប្រទេសជប៉ុន** និងកំពុង**មានប្រតិបត្តិការអាជីវកម្មនៅ៩ប្រទេស** រួមមាន ប្រទេសជប៉ុន សហរដ្ឋអាមេរិក វៀតណាម ឥណ្ឌា អូស្ត្រាលី ឥណ្ឌូនេស៊ី កម្ពុជា មីយ៉ាន់ម៉ា និងនូវែលសេឡង់។ ក្រុមហ៊ុន ដាយ អ៊ិឈិ ឡាយហ្វ៍ ហូលឌីង មានគ្រឹះមូលធនដ៏រឹងមាំជាមួយទ្រព្យសម្បត្តិសរុបចំនួន **៤៦៤.៣ ពាន់លានដុល្លារ** និងបុព្វលាភធានារ៉ាប់រងជាង **៤៥.៣ ពាន់លានដុល្លារ** (គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៥)។

ក្រុមហ៊ុន ដាយ អ៊ិឈិ ឡាយហ្វ៍ ចាប់ផ្ដើមប្រតិបត្តិការអាជីវកម្មនៅកម្ពុជាក្នុងឆ្នាំ២០១៩ និងមានទីស្នាក់ការកណ្ដាលស្ថិតនៅរាជធានីភ្នំពេញ និងការិយាល័យសាខានៅខេត្តបាត់ដំបង និងខេត្តសៀមរាប។ ក្រុមហ៊ុនទទួលបានពានរង្វាន់ជា **«ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតអន្តរជាតិល្អបំផុតប្រចាំឆ្នាំនៅក្នុងប្រទេសកម្ពុជា»** រយៈពេល២ឆ្នាំជាប់គ្នាគឺឆ្នាំ២០២៣ និង ២០២៤។ ថ្មីៗនេះយើងក៏ទទួលបានពានរង្វាន់២បន្ថែមទៀតពី **HR Asia** ក្នុងនាមជា **«ស្ថាប័នការងារល្អបំផុតនៅអាស៊ី»** និង **«ពានរង្វាន់ក្រុមហ៊ុនដែលគិតគូរពីបុគ្គលិកបំផុត»** ប្រចាំឆ្នាំ២០២៤។

គិតត្រឹមខែមករា ឆ្នាំ២០២៥ ក្រុមហ៊ុន ដាយ អ៊ិឈិ ឡាយហ្វ៍ កំពុងផ្ដល់ការការពារផ្នែកហិរញ្ញវត្ថុជូនប្រជាជនកម្ពុជាចំនួន **១ម៉ឺន៣ពាន់គ្រួសារ** ជាមួយទំហំទឹកប្រាក់ការពារចំនួន **៩១លានដុល្លារអាមេរិក**។ កន្លងមក ក្រុមហ៊ុនបានទូទាត់សំណង និងអត្ថប្រយោជន៍ផ្សេងៗជូនដល់អតិថិជនចំនួនជាង **១ពាន់២រយគ្រួសារ** ក្នុងទំហំទឹកប្រាក់ជាង **៥៩ម៉ឺនដុល្លារអាមេរិក**។


**សម្រាប់ព័ត៌មានបន្ថែម**
**1800 201 202**

ក្រុមហ៊ុន ដាយ អ៊ិឈិ ឡាយហ្វ៍ អ៊ីនស្ហួរិនស៍ (ខេមបូឌា) ម.ក
ជាន់ផ្ទាល់ដី ជាន់ទី១ និងជាន់ទី២ អគារសាមគ្គី ផ្លូវលេខ៣១៥ ភូមិ៦
សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ


# ងាយៗក្នុងការទទួលបានការការពារអាយុជីវិត

## តាមរយៈសេវាកម្មអនឡាញ ជាមួយនឹងតម្លៃសមរម្យ សម្រាប់ការធានារ៉ាប់រងក្នុងរយៈពេលមួយឆ្នាំពេញ

| កញ្ចប់គម្រោងការពារអាយុជីវិត | គម្រោងប្រាក់ប្រាយឡាយហ្វ៍ | គម្រោងមាសប្រាយឡាយហ្វ៍ | គម្រោងពេជ្រប្រាយឡាយហ្វ៍ |
|---|---|---|---|
| ទំហំទឹកប្រាក់ត្រូវបានធានា | 2,500 ដុល្លារអាមេរិក | 5,000 ដុល្លារអាមេរិក | 10,000 ដុល្លារអាមេរិក |
| រយៈពេលនៃការធានារ៉ាប់រង | 1 ឆ្នាំពេញ | | |
| ការបង់បុព្វលាភធានារ៉ាប់រង | បង់តែមួយដងគត់ | | |
| ការការពារហានិភ័យ | មរណភាព ឬពិការភាពទាំងស្រុង និងអចិន្ត្រៃយ៍ | | |
| គុណតម្លៃ | ចូលរួមចំណែកដើម្បីជួយសម្រេចនូវក្ដីសុបិន្តរបស់លោកអ្នក ក្នុងការពារពារក្រុមគ្រួសារ និងមនុស្សជាទីស្រលាញ់ អោយជៀសផុតពីបន្ទុកហិរញ្ញវត្ថុ ប្រឆាំងនឹងហេតុការណ៍អកុសលណាមួយដែលអាចកើតឡើងជាយថាហេតុ។ | | |

### ឧទាហរណ៍ទី១

លោក ដារ៉ា អាយុ 35ឆ្នាំ ទិញ**គម្រោងមាស** ពីគម្រោងមូលដ្ឋាន ប្រាយឡាយហ្វ៍ ដែលបណ្ណសន្យារ៉ាប់រងមានរយៈពេល **1ឆ្នាំ** ជាមួយនឹងទំហំទឹកប្រាក់ត្រូវបានធានា 5.000 ដុល្លារអាមេរិក។

### ការការពារ

